(1)

13

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

+++++

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តបាត់ដំបង

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៤១៩
ចុះថ្ងៃទី ១៦/០៦/២០០៨
សាលក្រមព្រហ្មទណ្ឌ
លេខ: ៨៤ ក
ចុះថ្ងៃទី ២៩/០៧/២០១០

កាលបរិច្ឆេទបើកសវនាការជាសាធារណៈនៅនាទីបន្ទប់ជំនុំជម្រះទី ១ ថ្ងៃទី ២៥.០៣.១០. ០៩.០៦.២០១០

កាលបរិច្ឆេទប្រកាសសាលក្រមជាសាធារណៈនៅនាទីបន្ទប់ជំនុំជម្រះទី ១ថ្ងៃទី ២៩ .០៧.២០១០

ចៅក្រមជំនុំជម្រះ : លោក [redacted] ចៅក្រមសាលាដំបូងខេត្ត

តំណាងអយ្យការ : លោក [redacted] . ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ : លោកស្រី [redacted]

ជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ:៤២៩ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ ដែលមានជនជាប់ចោទ :

១-ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានទីកន្លែងកំណើតភូមិ [redacted] ។ ទីលំនៅសព្វថ្ងៃភូមិ [redacted] មុខរបរធ្វើស្រែ កំរិតវប្បធម៌ថ្នាក់ទី១០ចាស់ កាន់សាសនាព្រះពុទ្ធ មានប្តីឈ្មោះ [redacted] មានកូន០៥នាក់ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] រ/ស ទោសពីមុនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន០៩ខែ ពីបទៈចោរកម្ម តែទោសនេះជាទោសព្យួរ ដោយមានលោកមេធាវី [redacted] រិទ្ធី ជាអ្នកការពារ។

---

២/ឈ្មោះ [redacted] ឆាន់ ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានប្រពន្ធឈ្មោះ [redacted] រ/ មានកូន០៥ នាក់ មានឪពុកឈ្មោះ [redacted] រ/ ម្តាយឈ្មោះ [redacted] រ/ មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី ១០ចាស់ ទោសពីមុនគ្មានដោយមានលោក ប៊ុន រិទ្ធី ជាមេធាវីការពារ ។

៣/ឈ្មោះ [redacted] ធួន ហៅ ឆាន់ ឈន ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី៨ថ្មី កាន់សាសនាព្រះពុទ្ធ នៅលីវ មានឪពុកឈ្មោះ [redacted] រ/ ម្តាយឈ្មោះ [redacted] រ/ ទោសពីមុនគ្មាន ដោយមានលោក [redacted] រិទ្ធី ជាមេធាវីការពារ ។

៤/ឈ្មោះ [redacted] ឆាង ហៅ ហ៊ាន ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរ ធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី៨ថ្មី កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] មានកូន០១ នាក់ មានឪពុកឈ្មោះ [redacted] រ/ ម្តាយឈ្មោះ [redacted] ហឿ រ/ ទោសពីមុនគ្មាន ដោយមានលោក [redacted] រិទ្ធី ជាមេធាវីការពារ ។

៥/ឈ្មោះ [redacted] ហន ភេទប្រុស អាយុ៥៧ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី៧ចាស់ កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] រី មានកូន០៦នាក់ មានឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ

Scanned with CamScanner

[redacted]ធិ ស ទោសពីមុនគ្មាន.ដោយមានលោក [redacted]ពិរោះ ជាមេធាវីការពារ ។

៦/ឈ្មោះ [redacted] សុឃឹម ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី ០៩ថ្មី កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ មានឪពុកឈ្មោះ [redacted] រ ម្តាយឈ្មោះ [redacted] រ ទោសពីមុនគ្មាន .ដោយមានលោក [redacted] រិទ្ធិ ជាមេធាវីការពារ ។

៧/ឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ កើតនៅ(ជុំសាយធុ) ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី០៦ថ្មី កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] រ មានកូន០១នាក់ មានឪពុកឈ្មោះ [redacted] រ ម្តាយឈ្មោះ [redacted] រ ទោសពីមុនគ្មាន. ដោយមានលោក [redacted] រិទ្ធិ ជាមេធាវីការពារ ។

៨/ឈ្មោះ [redacted] សិត ភេទប្រុស អាយុ៥៦ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ។ ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ កំរិតវប្បធម៌គ្មាន កាន់សាសនាព្រះពុទ្ធ ពោះម៉ាយ មានកូនចំនួន០៦នាក់ មានឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ស ទោសពីមុនគ្មាន ។

៩/ឈ្មោះ [redacted] ខន ភេទប្រុស អាយុ៣៨ឆ្នាំ.សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី០២ថ្មី កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ មានឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ស ទោសពីមុនគ្មាន.ដោយលោក [redacted] រិទ្ធិ ជាមេធាវីការពារ ។

១០/ឈ្មោះ [redacted] [illegible] ភេទប្រុស អាយុ៦៨ឆ្នាំ សញ្ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃភូមិ [redacted] មានមុខរបរធ្វើស្រែ មានកំរិតវប្បធម៌ថ្នាក់ទី៤ចាស់ កាន់សាសនាព្រះពុទ្ធ មានប្រពន្ធឈ្មោះ [redacted] មានឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ស ទោសពីមុនគ្មាន .ដោយមានលោក [redacted] ពិរោះ ជាមេធាវីការពារ ។

ត្រូវជាប់ចោទពីបទ : ចោរកម្ម និង ប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិព្រៃចក និង ភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល និង មាត្រា២៤៨.២៥៣ នៃច្បាប់ភូមិបាល ។

តាមដីកាបញ្ជូនរឿងឱ្យជំនុំជម្រះលេខ ៤៧៧៧ ភស.ព្រទ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរ ។

<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>

១-ឈ្មោះ [redacted] មុត ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted]

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៧.០០០.០០០រៀល ( ប្រាំពីរលានរៀលគត់ )

២-ឈ្មោះ [redacted] ព្រុំ ភេទប្រុស អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណងនិង ជម្ងឺចិត្តជាប្រាក់ចំនួន ៨.០០០.០០០រៀល( ប្រាំបីលានរៀលគត់) ឯជនល្មើសសុំឱ្យផ្តន្ទាទោសទៅតាមច្បាប់ ។

៣-ឈ្មោះ [redacted] ហ៊ាន ភេទប្រុស អាយុ៦៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ៨.០០០.០០០ ( ប្រាំបីលានរៀលគត់) ជនល្មើសសុំឱ្យផ្តន្ទាទោសទៅតាមច្បាប់ ។

៤-ឈ្មោះ [redacted] សឿត ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ១៣.០០០.០០០រៀល( ដប់បីលានរៀលគត់) និង សុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

៥-ឈ្មោះ [redacted] គឹម ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ៥.០០០.០០០ រៀល ( ប្រាំលានរៀលគត់) ។

៦-ឈ្មោះ [redacted] រ៉េន ភេទប្រុស អាយុ៤៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំប្តឹងទាមទារសំណងខូចខាត និង ជម្ងឺចិត្តជាប្រាក់ចំនួន ១២.០០០.០០០រៀល ( ដប់ពីរលានរៀលគត់) ។

៧-ឈ្មោះ [redacted] ម៉ៅ ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិស៊ឹង [redacted] ។

ខ្លួនសំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណង និងជម្ងឺចិត្តចំនួន ៦.០០០.០០០រៀល ( ប្រាំមួយលានរៀលគត់) ឯជនល្មើសសុំឱ្យផ្តន្ទាទោសទៅតាមច្បាប់ ។

៨-ឈ្មោះ [redacted] ឡឹង ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted]

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ១២.០០០.០០០រៀល ( ដប់ពីរលានរៀលគត់) និង សុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

៩-ឈ្មោះ [redacted] ង៉ា ភេទប្រុស អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៦.០០០.០០០រៀល ( ប្រាំមួយលានរៀលគត់) ហើយសុំឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១០-ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ៥៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted] ។

Scanned with CamScanner

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ៨.៤០០.០០០ រៀល (ប្រាំបីលានបួនសែនរៀល) និង សុំឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១១-ឈ្មោះ [redacted] ឡា ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ១៣.៥០០.០០០រៀល (ដប់បីលានប្រាំសែនរៀល) និងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

១២-[redacted] កិញ្ញ ប៊ុត ភេទប្រុស អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និងសុំប្តឹងទាមទារសំណងព្រមទាំងជម្ងឺចិត្តជាប្រាក់ចំនួន ១៥.០០០.០០០រៀល (ដប់ប្រាំលានរៀលគត់) និងសុំឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១៣-ឈ្មោះ [redacted] ទិត ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០.០០០.០០០រៀល (ដប់លានរៀលគត់) ហើយសុំឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១៤-ឈ្មោះ [redacted] ខ្ញឹង ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ និង សុំប្តឹងទាមទារសំណង និងជម្ងឺចិត្តជាប្រាក់ចំនួន ៦.៦០០.០០០រៀល (ប្រាំមួយលាន ប្រាំមួយសែនរៀលគត់) ហើយសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១៥-ឈ្មោះ [redacted] ភី ភេទប្រុស អាយុ៦១ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ១០.០០០.០០០រៀល (ដប់លានរៀលគត់) និង សុំឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១៦-ឈ្មោះ [redacted] សឿក ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន១២.០០០.០០០រៀល (ដប់ពីរលានរៀល) ហើយសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

១៧-ឈ្មោះ [redacted] ទិត ភេទប្រុស អាយុ.......ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ។

ក្នុងរឿងនេះខ្លួនសុំឱ្យសមត្ថកិច្ចជួយរកយុត្តិធម៌ និង ចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់ និង សុំទាមទារសំណង ខូចខាតគោជិះស្រែចំនួន ៥ ក្បាល ក្នុង ១ក្បាលតម្លៃ២០០ដុល្លារ សរុប ១០០០ដុល្លារ (មួយពាន់ដុល្លារ) ។

១៨-ឈ្មោះ [redacted] [illegible] ភេទប្រុស អាយុ[illegible]ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted]

Scanned with CamScanner

[redacted]

ក្នុងរឿងនេះខ្ញុំសុំឱ្យតុលាការជួយរកយុត្តិធម៌ ព្រោះដីនេះខ្ញុំបានទិញត្រឹមត្រូវ ហើយបានចែកឱ្យប្រជាពលរដ្ឋត្រឹមត្រូវ ចំពោះដីដែលនៅសល់ខ្ញុំសុំគ្រប់គ្រងស្របច្បាប់ ។

-បានឃើញរបាយការណ៍លេខ ០២៥/ករ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់មេភូមិកុយវែង(ឯកសារលេខ ២)

-បានឃើញរបាយការណ៍លេខ ០២៦/ករ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់មេភូមិកុយវែង (ឯកសារលេខ ៣ ។

-បានឃើញរបាយការណ៍លេខ ០៧ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់មេភូមិព្រៃចក របស់មេភូមិកុយវែង (ឯកសារលេខ៤) ។

-បានឃើញរបាយការណ៍លេខ ០២៨/ករ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់មេភូមិកុយវែង(ឯកសារលេខ៥)

-បានឃើញរបាយការណ៍លេខ ០៣២/ករ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់មេភូមិកុយវែង (ឯកសារលេខ៦)

-បានឃើញកំណត់ហេតុសួរចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ម៉ូក . [redacted] ព្រុំ . [redacted] ហាន . [redacted] សៀក . [redacted] គិម . [redacted] វ៉ន . [redacted] ម៉ៅ . [redacted] ឡឹង. [redacted] ង៉ា [redacted] ហ៊ាន . [redacted] ឡា . [redacted] ប៊ុត . [redacted] ទិត . [redacted] ខ្លឹង [redacted] អ៊ូ . [redacted] សឿត . និង ឈ្មោះ [redacted] ឡៀងឡេង (ឯកសារលេខ ៣១.៣២.៣៣.៣៤.៣៥.៣៦.៣៩.៤០.៤១.៤២.៤៣.៤៤.៤៥.៤៦. ៤៧.៤៨ និង ឯកសារលេខ ៧៦ ) ។

-បានឃើញកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ហាន . [redacted] រិន . [redacted] ប៉ូច . [redacted] ណាង . [redacted] ឆាន់. [redacted] រ៉ុត [redacted] ជីន [redacted] ជឿន . [redacted] សុឃឹម . [redacted] ខន [redacted] ហ៊ិត [redacted] ជឹម . [redacted] សុខ និង [redacted] ខុន(ឯកសារលេខ៥៧.៦០.៦៣.៦៦.៧៣.៧៨.៨០.៨៤.៨៧.៩៨.១០១.១០៤.១០៧.និង លេខ ១០៩) ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៤៤១ ដស.សព ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ របស់ព្រះរាជអាជ្ញា អម សាលាដំបូងខេត្តកំពង់ចាម (ឯកសារលេខ ១២០

-បានឃើញដីកាបញ្ជូនរឿងឱ្យជំនុំជម្រះលេខ ៤៧៧ ពស.ព្រទ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ របស់ចៅក្រម ស៊ើបសួរ(ឯកសារលេខ ១២៣)

<u>នៅចំពោះមុខតុលាការនាពេលសវនាការ</u>

-ក្រោយពីបានធ្វើនីតិវិធីសាកសួរជេញដោល នាពេលសវនាការជំនុំជម្រះ បានចប់សព្វគ្រប់ ។

-ក្រោយពីបានពិនិត្យលើកំណត់ហេតុសវនាការជំនុំជម្រះលេខ ៤៣ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ។

-ក្រោយពីបានពិនិត្យលើកំណត់ហេតុសវនាការជំនុំជម្រះលេខ ៩៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

Scanned with CamScanner

តុលាការខេត្តបាត់ដំបង

យល់ឃើញថាៈ

-ជនជាប់ចោទឈ្មោះ [redacted] ហន.[redacted] សុឃិម.[redacted] ជឿន.[redacted] សិក.សឿន [redacted] ហា រិន ហៅ [redacted] ចាន់ ហឿ ហៅ [redacted] សុខ ឆាន់.[redacted] ធូន ហៅ [redacted] ឈន និង ឈ្មោះ [redacted] ឆាង ហៅ ហ៊ាន ពិតជាបានប្រព្រឹត្តនូវអំពើចោរកម្ម និង ប៉ះពាល់កម្មសិទ្ធឯកជន កាលពីថ្ងៃទី២៨ ខែវិច្ឆកា ដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ នៅភូមិកុយវែង និង ភូមិព្រៃចក ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលបំពានលើមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ២៤៨.២៥៣ នៃច្បាប់ភូមិបាល ។

-ជនជាប់ចោទឈ្មោះ [redacted] ហន [redacted] សុឃិម.[redacted] ជឿន [redacted] សិក.សឿន ខន និងឈ្មោះ [redacted] រិន [redacted] ភាភេ បានទទួលស្គាល់នូវកំហុសដែលបានប្រព្រឹត្តកន្លងមកហើយទទួលនូវការធ្វើសម្បទាន របស់ម្ចាស់កម្មសិទ្ធ ដោយពុំមានទាមទារអ្វីទៀតឡើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ហឿ ហៅ [redacted].សុខ ឆាន់.[redacted] ធូន ហៅ [redacted] ឈន និង ឈ្មោះ [redacted] ឆាង ហៅ ហ៊ាន មិនព្រមទទួលស្គាល់នូវកំហុសដែលបានប្រព្រឹត្តកន្លងមក. ហើយ នូវតែធ្វើការបំពារបំពានទៅលើដីដែលមិនមែនជាកម្មសិទ្ធរបស់ខ្លួន ។

-ដើមបណ្តឹងប្តឹងទាមទារសំណងអន្តរាយតែពុំមានការបញ្ជាក់ច្បាស់លាស់ ទុកសិទ្ធ ប្តឹងទាមទារសំណងតាមបណ្តឹងរដ្ឋប្បវេណី នៅពេលក្រោយ ។

ហេតុដូច្នេះសម្រេច

ដំអច

១/ផ្តន្ទាទោសឈ្មោះ :

ក/១-ឈ្មោះ [redacted] ហ៊ុន ភេទប្រុស អាយុ៥៧ឆ្នាំ សញ្ជាតិខ្មែរ

២-ឈ្មោះ [redacted] សុឃឹម ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ

៣-ឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ

៤-ឈ្មោះ [redacted] សិក ភេទប្រុស អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ

៥-ឈ្មោះ [redacted] ខន ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ

៦-ឈ្មោះ [redacted] រិន ហៅ ភាភេ ភេទប្រុស អាយុ៦៧ឆ្នាំ សញ្ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ ( មួយឆ្នាំគត់ ) ក្នុងម្នាក់ៗ តែទោសនេះត្រូវព្យួរ ។

ខ/១-ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ភេទស្រី អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ

២-ឈ្មោះ [redacted] ឆាន់-ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ

៣-ឈ្មោះ [redacted] ធូន ហៅ ឆាន់ ឈន ភេទប្រុស អាយុ២៨ឆ្នាំ សញ្ជាតិខ្មែរ

៤-ឈ្មោះ [redacted] ឆាង ហៅ ហ៊ាន ភេទប្រុស [illegible]ឆ្នាំ សញ្ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ ( មួយឆ្នាំគត់ [illegible] សាលក្រមចូលជាស្ថាពរ ។

Scanned with CamScanner

ពិរុទ្ធ : ចោរកម្ម និង បំពានលើកម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិព្រៃចេក និង ភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល និង មាត្រា២៤៨.២៥៣ នៃច្បាប់ភូមិបាល ។

២/ចំពោះសំណងអន្តរាយពុំមានការបញ្ជាក់ច្បាស់លាស់ទុកសិទ្ធិឱ្យដើមបណ្តឹង ប្តឹងទាមទារសំណងរដ្ឋប្បវេណីនៅពេលក្រោយ ។

៣/សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ន. [redacted] សុឃីម. [redacted] ជឿន. [redacted] សិត. [redacted] ខន. [redacted] ឆាន់. [redacted] រិន ហៅ [redacted] កេ . [redacted] ឆាង ហៅ ហ៊ុន និង ឈ្មោះ [redacted] ហឿ ហៅ ម៉ៅ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ង៉ា . [redacted] រ៉េន . [redacted] ឡឹង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ធួន ហៅ [redacted] និង ដើមបណ្តឹងឈ្មោះ [redacted] សឿត. [redacted] កើត. [redacted] និត. [redacted] អ៊ូ. ភួង ខ្វិង. [redacted] ម៉ៅ. ឆន ហ៊ាន. [redacted] ប៊ុត. [redacted] ព្រំ. [redacted] មួត. [redacted] ហាន. [redacted] គិម. [redacted] សឿត. [redacted] និត . [redacted] ឡា ។

ទុកសិទ្ធិប្តឹងទាស់ និង ឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និង ត្រា មូ សម្ផស្ស

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និង ត្រា ទៅ យ៉ារ័ត្ន

---

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម

បាត់ដំបង ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១០

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

បាត់ដំបង ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១០

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner